**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ៖ ៣៣៣/២៥ សរក

**សូមគោរពជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ស ថេត អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**
**អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារអនុវត្តច្បាប់**

**កម្មវត្ថុ៖** សំណើសុំផ្តល់កិច្ចសហការ និងសូមចាត់សមាសភាពមន្ត្រីនគរបាល ចំនួន ១០រូប ដើម្បីរៀបចំផលិតវីដេអូបទយកការណ៍ សម្រាប់ផ្សព្វផ្សាយ ក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ។

**យោង៖** ចំណារដ៏ខ្ពង់ខ្ពស់បំផុត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារអនុវត្តច្បាប់** មេត្តាជ្រាបថា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយក្រុមហ៊ុន សាស្ត្រាហ្វីម (Sastra Film Production) ដើម្បីផលិតជាវីដេអូបទយកការណ៍សម្រាប់ផ្សព្វផ្សាយ ក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំ **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ** ដើម្បីផ្តល់**កិច្ចសហការ និងសម្របសម្រួល ព្រមទាំងចាត់សមាសភាពមន្ត្រីនគរបាល តាមការស្នើសុំមានដូចខាងក្រោម៖**

| | |
|---|---|
| **១-សមាសភាពមន្ត្រីនគរបាល (ឯកសណ្ឋានការងារលេខ៧)** | **ចំនួន ១០រូប** |
| **២-រថយន្តនគរបាលដឹកក្រុមជនល្មើស ដែលអាចផ្ទុកបានចំនួន១០នាក់** | **ចំនួន ០១គ្រឿង** |
| **៣-រថយន្តនគរបាលមានបំពាក់ស៊ីរ៉ែន** | **ចំនួន ០១គ្រឿង** |

**កម្មវិធីថតនឹងប្រព្រឹត្តទៅនៅ៖ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ០៧:០០ នាទីយប់ ។**

*(សូមគោរពជូនភ្ជាប់៖ កម្មវិធី ០១ច្បាប់)*

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ** មេត្តាផ្តល់កិច្ចសហការ និងសម្របសម្រួលតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

*ថ្ងៃ អង្គារ ១២ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២៥*

**អគ្គលេខាធិការ**

**ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់**

សូមទំនាក់ទំនង៖
លោក វ.ទោ ធន ដារ៉ាវិទ្ធ
០១៦ ៩០ ៨៩ ៨៨